Minnesota Department of Education

សំណួរ និងចម្លើយស្តីពីលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា

តើលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាគឺជាអ្វី?

ដើម្បីមានលក្ខណសម្បត្តិសម្រាប់ទទួលលិខិតបញ្ជាក់ការសិក្សាពីវិទ្យាល័យរដ្ឋមីណេសូតា សិស្សទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា។ អាស្រ័យដោយមានការកែសម្រួលលក្ខន្តិក: មីណេសូតា ហេតុនេះលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សានៅផ្នែក 120B.30 ក៏បានផ្លាស់ប្តូរដែរ។ មានវិធីសាស្ត្រផ្សេងគ្នាដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា អាស្រ័យទៅតាមឆ្នាំដែលសិស្សបានចុះឈ្មោះចូលរៀនដំបូងនៅថ្នាក់ទី 8។ មាតាបិតា/អាណាព្យាបាលគួរទាក់ទងសាលារៀនរបស់កូនពួកគេសម្រាប់ព័ត៌មានបន្ថែម។

ជាមួយនឹងការផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា ព័ត៌មានលម្អិតនិងព័ត៌មានបន្ថែមនឹងបន្តផ្តល់នៅលើវិបសាយ MDE តាមការចាំបាច់។ [សូមអានផ្នែក Just for Parents (សម្រាប់តែមាតាបិតា) នៃវិបសាយ MDE សម្រាប់ព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត]។ (សូមមើលព័ត៌មាននៃការធ្វើតេស្ត > សម្រាប់តែមាតាបិតា។)

តើមានវិធីសាស្ត្រណាដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សារបស់រដ្ឋ?

សិស្សថ្នាក់ទី 12 និងសិស្សចាស់ជាងនេះនៅឆ្នាំសិក្សា 2014–2015 (បានចុះឈ្មោះចូលរៀននៅថ្នាក់ទី 8 ក្នុងឆ្នាំ 2010–2011 ឬមុននេះ)

សិស្សទាំងនេះអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាក្នុងមុខវិជ្ជា អំណាន គណិតវិទ្យា និងតែងសេចក្តីតាមរយៈការបញ្ចូលជម្រើសទាំងបីដែលបានកំណត់ក្នុងខណៈពេលដែលលក្ខខណ្ឌតម្រូវត្រូវបានបំពេញតាមមុខវិជ្ជានីមួយៗ។

1. បំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាតាមរយៈការវាយតម្លៃដែលចាំបាច់សម្រាប់បញ្ចប់ការសិក្សាដើម្បីបានលិខិតបញ្ជាក់ការសិក្សាក្នុងមុខវិជ្ជាអំណាន គណិតវិទ្យា និងតែងសេចក្តី ដែលរួមមាន៖

- ការទទួលបានពិន្ទុគ្រប់គ្រាន់។ ប្រសិនបើសិស្សទទួលបានពិន្ទុខ្ពស់ (ទទួលបានពិន្ទុដែលបានកំណត់ ឬលើសពីស្តង់ដារ) ស្តីពីការវាយតម្លៃទូទៅរបស់មីណេសូតានៃមុខវិជ្ជាតែងសេចក្តីសម្រាប់ថ្នាក់ទី 10 (MCA) និងមុខវិជ្ជាគណិតវិទ្យាសម្រាប់ថ្នាក់ទី 11 ពួកគេបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាសម្រាប់មុខវិជ្ជាទាំងពីរនេះ។
    - ការវាយតម្លៃនេះត្រូវបានអនុវត្តចំពោះសិស្សដែលធ្វើការវាយតម្លៃទូទៅរបស់មីណេសូតាថ្នាក់វិទ្យាល័យ ឬការសាកល្បងជំនាញសិក្សារបស់មីណេសូតា (MTAS) ក្នុងកន្លែងនៃ MCAs។
- ការទទួលបានពិន្ទុជាប់នៅលើមុខវិជ្ជា តែងសេចក្តី GRAD ឬអំណាន និង GRAD តេស្តគណិតវិទ្យាឡើងវិញ។
    - ការវាយតម្លៃតាមវិធីជំនួសរបស់មីណេសូតា៖ ការសរសេរអាចត្រូវបានផ្តល់ដល់សិស្សដែលត្រូវការការវាយតម្លៃតាមវិធីជំនួសដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការសរសេរ។
- ការបំពេញតាមវិធីសាស្ត្រជំនួសរបស់ GRAD អាចមានដូចខាងក្រោម៖
    - ទទួលបានពិន្ទុជាប់នីមួយៗ (សម្រាប់សិស្សថ្នាក់ IEP ឬផែនការ 504)
    - ទទួលបានការលើកលែងរៀនភាសាអង់គ្លេស (EL)
    - ជាប់ការវាយតម្លៃគណនេយ្យភាពពីរដ្ឋផ្សេងទៀតដែលបានអនុម័តដោយ MDE (ទៅវិញទៅមក)
    - បំពេញតាមលក្ខខណ្ឌតម្រូវនៃវិធីជំនួសមុខវិជ្ជាគណិតវិទ្យា (កត់សម្គាល់ថា នេះគឺអាចប្រើប្រាស់បានសម្រាប់សិស្សដែលមានអាយុចាស់ជាងសិស្សថ្នាក់ទី 12 ព្រោះវាជាជម្រើសតែមួយប៉ុណ្ណោះសម្រាប់សិស្សដែលបានចុះឈ្មោះចូលរៀនដំបូងនៅថ្នាក់ទី 8 ក្នុងឆ្នាំសិក្សា 2009–2010)

ឬ

2. សិស្សអាចធ្វើការវាយតម្លៃតាម ACT សម្រាប់ការចូលរៀនថ្នាក់មហាវិទ្យាល័យ ការវាយតម្លៃជំនាញការងា WorkKeys តេស្តចូលរៀនមហាវិទ្យាល័យ ឬការកំណត់សមត្ថភាពស្តីពីវិជ្ជាជីវៈ: បម្រើកងទ័ព (ឬ ASVAB) ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាក្នុងការអាន គណិតវិទ្យា និង/ឬ ការសរសេរ។

ឬ

3. មណ្ឌលសាលាក៏អាចជំនួសពិន្ទុពីវិធីជំនួស ការវាយតម្លៃដែលមានតម្លៃស្មើដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា។

សិស្សថ្នាក់ទី 11 នៃឆ្នាំសិក្សា 2014–2015 (ដែលបានចុះឈ្មោះដំបូងក្នុងថ្នាក់ទី 8 ក្នុងឆ្នាំសិក្សា 2011–2012)

សិស្សទាំងនេះនឹងធ្វើការសរសេរតាម ACT នៃកម្រិតថ្នាក់ទី 11 បូកនឹងការសរសេរ (ការប្រឡងចូលមហាវិទ្យាល័យ) ក្នុងពេលចុះឈ្មោះចូលរៀននៅទូទាំងរដ្ឋក្នុងឆ្នាំសិក្សា 2014–2015 លើផ្នែកការសរសេរ អំណាន និងគណិតវិទ្យាដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា។

ប៉ុន្តែ ប្រសិនបើសិស្សម្នាក់មិនអាចចូលរួមក្នុងការប្រឡងក្នុងថ្នាក់ទី 11 នៃ ACT បូកនឹងការសរសេរក្នុងឆ្នាំសិក្សា 2014–2015 សិស្សនោះអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាលើមុខវិជ្ជា អំណាន គណិតវិទ្យា តាមរយៈជម្រើសបីរួមគ្នាដែលមានបង្ហាញនៅក្នុង "សិស្សថ្នាក់ទី 12 ឬចាស់ជានៅក្នុងឆ្នាំសិក្សា 2014–2015 ។"

សិស្សថ្នាក់ទី 10 និងសិស្សក្មេងជាងនេះក្នុងឆ្នាំសិក្សា 2014–2015 (ដែលបានចុះឈ្មោះដំបូងនៅថ្នាក់ទី 8 ក្នុងឆ្នាំសិក្សា 2012–2013 និងក្រោយនេះ)

សិស្សទាំងនេះនឹងបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាតាមរយៈការចូលរួមក្នុងវគ្គអាជីពជាបន្តបន្ទប់ និងការវាយតម្លៃសម្រាប់ថ្នាក់មហាវិទ្យាល័យដែលនឹងត្រូវបានផ្តល់ជូនដំបូងក្នុងឆ្នាំសិក្សា 2014–2015៖

- ធ្វើតេស្ត ACT សម្រាប់ថ្នាក់ទី 8 វគ្គស្វែងរកអាជីព និងការវាយតម្លៃសម្រាប់ថ្នាក់មហាវិទ្យាល័យ (កំណត់សម្គាល់៖ ការវាយតម្លៃនេះមិនបានប្រើប្រាស់នៅទូទាំងរដ្ឋសម្រាប់សិស្សថ្នាក់ទី 8 ឆ្នាំសិក្សា 2013–2014 ទេ។)

និង

- ធ្វើតេស្ត ACT សម្រាប់ថ្នាក់ទី 10 ធ្វើផែនការអាជីព និងការវាយតម្លៃសម្រាប់ថ្នាក់មហាវិទ្យាល័យ

ដែលអាច

- ធ្វើតេស្ត ACT សម្រាប់ចូលរៀនថ្នាក់មហាវិទ្យាល័យ (ការវាយតម្លៃវិភាគសម្រាប់ការប្រឡងថ្នាក់មហាវិទ្យាល័យ)
    - សិស្សដែលមិនទាន់ត្រៀមខ្លួនសម្រាប់ការចាប់យកអាជីព ឬចូលរៀននៅថ្នាក់មហាវិទ្យាល័យដោយអាស្រ័យលើការរីកចម្រើនក្នុងការទទួលជោគជ័យលើការសិក្សារវាងសិស្សថ្នាក់ទី 8 និងថ្នាក់ទី 10 (ដែលបានកំណត់ដោយការអនុវត្តសិក្សាស្តីពីការវាយតម្លៃសិស្សថ្នាក់ទី 8 និងសិស្សថ្នាក់ទី 10) ត្រូវប្រឡងវិភាគសមត្ថភាពចូលរៀនថ្នាក់មហាវិទ្យាល័យ មុនពេលប្រឡងចូលថ្នាក់មហាវិទ្យាល័យនៅក្នុងនិទាឃរដូវ។

និង

- ធ្វើតេស្ត ACT សម្រាប់ថ្នាក់ទី 11 បូកនឹងតេស្តសរសេរដើម្បីចុះឈ្មោះចូលរៀននៅទូទាំងរដ្ឋ (ការប្រឡងចូលរៀនមហាវិទ្យាល័យ)

ព័ត៌មានបន្ថែមស្តីពីការចូលរួមរបស់សិស្សជាមួយកម្មវិធីអប់រំដោយឡែក ព្រមទាំងសិស្សនៅក្នុងស្ថានភាពពិសេស (ដូចជា សិស្សដែលចូលរៀនបន្ទាប់ពីចុះឈ្មោះចូលរៀនក្នុងពេលវាយតម្លៃអាជីព និងការចូលរៀននៅថ្នាក់មហាវិទ្យាល័យ) នឹងត្រូវបានផ្តល់នៅលើវិបសាយ MDE នៅពេលមានបន្ថែមថ្មី។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ការធ្វើតេស្តទូទាំងរដ្ឋ

mde.testing@state.mn.us

ក្រសួងអប់រំ មីណេសូតា

1500 Highway 36 West

Roseville, MN 55113-4266

http://education.state.mn.us

ខែឧសភា ឆ្នាំ 2014